# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ដែលមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល មានតួនាទីជាសេនាធិការជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យការបំពេញតួនាទី និងភារកិច្ចរបស់មន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ ធ្វើអធិការកិច្ចលើបណ្តាអង្គភាពនានាស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ និងទទួលពិនិត្យ សិក្សា ស្រាវជ្រាវ និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យ សំរេចលើវិវាទរដ្ឋបាល ពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធជាមួយមន្ត្រីរាជការក្រោមឱវាទក្រសួងមហាផ្ទៃ ។

មាត្រា ៣ : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល មានភារកិច្ចដូចខាងក្រោម :

- ធ្វើអធិការកិច្ចនៅតាមអង្គភាពថ្នាក់កណ្តាល និង ថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមឱវាទក្រសួងមហាផ្ទៃ ទាំងផ្នែករដ្ឋបាលស៊ីវិល និងនគរបាល តាមកំណត់នៃឆ្នាំនីមួយៗ ។
- ត្រួតពិនិត្យសកម្មភាពការងារ និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាល និងមន្ត្រីនគរបាលនៅថ្នាក់កណ្តាល និងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំណុះក្រសួងមហាផ្ទៃ ក្នុងការអនុវត្តផែនការសកម្មភាពរបស់ក្រសួងមហាផ្ទៃ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងច្បាប់រដ្ឋ ។
- សហការជាមួយអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ក្នុងការលើកសំណើជូនរដ្ឋមន្ត្រី ដើម្បីពិនិត្យ សំរេចផ្អាកការងារបណ្តោះអាសន្ន ចំពោះមន្ត្រីដែលពាក់ព័ន្ធកំហុសធ្ងន់ធ្ងរ ដើម្បីទុកឱកាសធ្វើការអង្កេតស្រាវជ្រាវ ។
- ក្នុងករណីពិនិត្យ និងស្រាវជ្រាវរកឃើញថា មន្ត្រីនានាស្ថិតក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ បានប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរ ដែលត្រូវស្នើអនុវត្តទណ្ឌកម្មខាងវិន័យ អគ្គាធិការដ្ឋានត្រូវពិភាក្សាជាមួយអង្គភាពសាមីដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី និងស្នើសុំយោបល់ពិនិត្យ សំរេចទៅលើរូបភាពទណ្ឌកម្មខាងវិន័យ ដែលនឹងត្រូវយកមកអនុវត្ត ឱ្យបានស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ។
- សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃទាំងនៅថ្នាក់កណ្តាល និង ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីប្រមូលពត៌មានដែលទាក់ទងដល់ការធ្វើអង្កេត ស្រាវជ្រាវ និងធ្វើអធិការកិច្ច។
- ណែនាំ និងបណ្តុះបណ្តាលដល់មន្ត្រីអគ្គាធិការដ្ឋាន លើជំនាញអធិការកិច្ចក្នុងការតាមដាន និងជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលរាជរដ្ឋាភិបាល និងក្រសួងបានដាក់ចេញ ។
- បន្ទាប់ពីបានទទួលបណ្តឹងតវ៉ា ឬបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋដល់មន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ អគ្គាធិការដ្ឋានត្រូវពិនិត្យ សិក្សា ស្រាវជ្រាវ និងលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសំរេចទៅលើវិធានការនានាស្របទៅតាមគោលការណ៍ច្បាប់ ។
- ចូលរួមពិនិត្យ ស្រាវជ្រាវ និងដោះស្រាយបណ្តឹងនានាជាមួយគណៈកម្មាការចំរុះអន្តរក្រសួង ក្នុងករណីមានការស្នើសុំ ។
- ចូកសរុបលទ្ធផលការងារ គ្រប់គ្រងឯកសារ ការងារបុគ្គលិក ភស្តុការ គណនេយ្យរបស់អគ្គាធិការដ្ឋាន តាមការកំណត់របស់ក្រសួង ។
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

មាត្រា ៤ : អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួន ជាជំនួយការ ។

អគ្គាធិការត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬមន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិជាឧត្តមសេនីយ៍ ។

អគ្គាធិការរងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពី វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិជាឧត្តមសេនីយ៍ ។

**មាត្រា ៥** : រចនាសម្ព័ន្ធរបស់អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានកំណត់ដូចខាងក្រោម :

- លេខាធិការដ្ឋាន
- អធិការដ្ឋានអធិការកិច្ច កិច្ចការនយោបាយរដ្ឋបាល
- អធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនយោបាយរដ្ឋបាល
- អធិការដ្ឋានអធិការកិច្ច កិច្ចការនគរបាល
- អធិការដ្ឋានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវកិច្ចការនគរបាល ។

**មាត្រា ៦** : អធិការដ្ឋានចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយអធិការមួយរូប និងមានអធិការរងមួយចំនួន ជាជំនួយការ ។

លេខាធិការដ្ឋាននៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវបានដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើនឹងអធិការរង នៃអធិការដ្ឋានចំណុះអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល ។

អធិការត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពី វរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិ ចាប់ពី វរសេនីយ៍ឯក ឡើងទៅ ។

អធិការរងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានឋានន្តរសក្តិ ចាប់ពីអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬពីក្នុងចំណោមមន្ត្រីនគរបាលជាតិ ដែលមានឋានន្តរសក្តិ ចាប់ពីវរសេនីយ៍ឯក ឡើងទៅ ។

**មាត្រា ៧** : តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់អធិការដ្ឋាន និង លេខាធិការដ្ឋាន នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៨** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី* *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៩*
- *ឯកសារ កាលប្បវត្តិ*